ទស្សនៈ
អ្នកនិពន្ធ

វ៉ុល៣, លេខ៥, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១

# តើបញ្ញវន្តសាធារណៈជាអ្នកណា? កើតឡើងដោយរបៀបណា?

អ៊ុន លាង *

"បញ្ញវន្តសាធារណៈ" ជាពាក្យដែលមានអត្ថន័យចម្រូងចម្រាស់បំផុត សូម្បីនៅកម្រិតសាកលលោក ពីព្រោះពាក្យនេះអាចសំដៅលើបុគ្គលិកលក្ខណៈមនុស្សផ្សេងៗ ដែលត្រូវបានកំណត់តាមស្ថានភាពដែលពួកគេចូលរួម ដូចដែលបានលើកឡើងដោយ **ហេង គីមគង់** ក្នុងអត្ថបទវិចារណកថារបស់លោកក្រោមចំណងជើងថា "តួនាទីបញ្ញវន្តសាធារណៈក្នុងសង្គមកម្ពុជា" (អត្ថបទដើមជាភាសាអង់គ្លេស) បោះពុម្ពដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រហែលជាអ្វីមួយដែលមានការព្រមព្រៀងគ្នាជារួមនោះ គឺសារសំខាន់នៃតួនាទីរបស់បញ្ញវន្តសាធារណៈក្នុងសង្គម។ ប្រសិនបើបញ្ញវន្តសាធារណៈពិតជាមានតួនាទីសំខាន់ ដែលមិនអាចអត់បានមែននោះ វាចាំបាច់បំផុតក្នុងការកំណត់និយមន័យនៃវាក្យស័ព្ទនេះឱ្យបានច្បាស់ជាមុន តាមរយៈសំណួរថា តើមានលក្ខណវិនិច្ឆ័យបែបណាខ្លះដើម្បីសម្គាល់/សំដៅនរណាម្នាក់ថាជាបញ្ញវន្តសាធារណៈ ជាពិសេសសម្រាប់សង្គមកម្ពុជា?

ពាក្យ "បញ្ញវន្តសាធារណៈ" ហាក់ដូចជាថ្មីណាស់ក្នុងបរិបទនៃប្រទេសកម្ពុជា ពីព្រោះវាមិនមាននៅក្នុងវចនានុក្រមខ្មែរនោះទេ ហើយទំនងជាត្រូវបានបកប្រែពីភាសាអង់គ្លេស "Public Intellectual" ដែលវាក្យស័ព្ទស្ទើរតែមាននៅក្នុងគ្រប់វចនានុក្រមភាសាអង់គ្លេសទាំងអស់។ ទោះបីជាខ្ញុំមិនយល់ស្របនឹងនិយមន័យនៃពាក្យនេះ តាមវចនានុក្រមទាំងនោះក៏ដោយ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា វត្តមានរបស់វានៅក្នុងវចនានុក្រម មានន័យថា នៅក្នុងពិភពបស្ចិមប្រទេស វាមានវប្បធម៌ និងចលនាបញ្ញវន្តសាធារណៈ ជាពិសេសចាប់ពីក្រោយសង្គ្រាមលោកលើកទី២[1]ខណៈពេលដែលនៅកម្ពុជា វប្បធម៌ និងចលនាបែបនេះនៅជារឿងថ្មីស្រឡាងមួយនៅឡើយ។

មានតែពាក្យ "បញ្ញវន្ត" ទេ ដែលមានពន្យល់ក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ប្រើសម្គាល់លើមនុស្សដែលមានប្រាជ្ញា (យល់ជាក់ច្បាស់) អ្នកយកចិត្តទុកដាក់ប្រើគំនិតត្រិះរិះក្នុងកិច្ចការគ្រប់ជំពូក។ ហើយជាទូទៅ សំដៅជាពិសេសលើអ្នកដែលទទួលបានការអប់រំខ្ពស់កម្រិតឧត្តមសិក្សា។

ជាលក្ខណៈប្រវត្តិសាស្ត្រ ដោយសារកង្វះអ្នកមានការអប់រំខ្ពស់ដើម្បីបម្រើសង្គម ទាំងក្រោយអាណានិគមនិយមបារាំង និងជាពិសេសក្រោយរបបខ្មែរក្រហម អ្នកមានការអប់រំខ្ពស់ ត្រូវបានស្នើសុំ និងផ្តល់ឱកាសឱ្យមកបម្រើការងារនៅក្នុងជួររដ្ឋាភិបាលដើម្បីកសាង និងអភិវឌ្ឍជាតិ។ ក្នុងន័យនេះ បញ្ញវន្តត្រូវបានសំដៅលើអ្នកដែលធ្វើការងារលើវិស័យសិក្សាធិការ

[1] ទោះបីជាចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ វប្បធម៌ និងចលនានេះកំពុងថមថយឋាមពលក៏ដោយ។ សូមមើល Richard A. Posner (2001). Public Intellectuals: A Study of Decline (Harvard University Press), A. Etzioni, & A. Bowdith (Eds.) (2006). Public Intellectuals: An Endangered Species? (Rowman & Littlefield)។

***លោកបណ្ឌិត អ៊ុន លាង** គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

និងសង្គមកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩០ តាមរយៈសមារហេណ-កម្មសដ្ឋកិច្ច និងការចាប់យកមូលធននិយម និងទីផ្សារសេរី និងសាកលភាវូបនីយកម្ម អ្នកមានការអប់រំខ្ពស់ដែលមិនបានបម្រើការងារលើវិស័យសិក្សាធិការ និងសង្គមកិច្ច ត្រូវបានចូលធ្វើការងារក្នុងវិស័យឯកជន និងមួយចំនួនក្នុងសង្គមស៊ីវិល។

នៅក្នុងន័យនេះ បញ្ញវន្តទាំងនេះនឹងរវល់ជាមួយអាជីពការងាររបស់ខ្លួន ប៉ុន្តែមិនបានចូលរួមក្នុងការពិភាក្សា និងជជែកអំពីនិយាមនៃវិចារណកិច្ចលើកិច្ចការ ដែលពួកគេកំពុងប្រតិបត្តិនោះទេ។ ចេញពីទស្សនវិស័យពួកគេ កំណែទម្រង់ឱ្យបានល្អ គឺជាការពិភាក្សាប្រកបដោយការប្រើប្រាស់បញ្ញារបស់ពួកគេ ដើម្បីសម្រេចបានគោលដៅ និងចូលរួមការអភិវឌ្ឍប្រទេស។ កម្ពុជាកំពុងខ្វះខាតបញ្ញវន្តដើម្បីបម្រើការងារក្នុងអាជីពទាំងអស់នេះ[2] ហើយការអភិវឌ្ឍ និងកំណែទម្រង់ឧត្តមសិក្សាអប់រំកំពុងពុះពារ ក្នុងការកសាងបញ្ញវន្តដើម្បីបំពេញកង្វះខាតទាំងនេះ។

សំណួរនៅទីនេះគឺថា តើអ្នកដែលទទួលបានការអប់រំជាន់ខ្ពស់ និងអ្នកសកម្មក្នុងការបញ្ចេញមតិក្នុងអាជីពការងារទាំងនេះ អាចត្រូវបានចាត់ទុកថាជាបញ្ញវន្តសាធារណៈ? តាមពិតបញ្ញវន្តសាធារណៈមិនមែនជាវណ្ណៈមួយដូចជា កសិករ ឬកម្មករនោះទេ ហើយក៏មិនមែនជាសមាជិកនៃអ្នកអាជីពការងារសង្គមដូចជាវិស្វករ មេធាវី ឬវេជ្ជបណ្ឌិត ឬអ្នកនៅក្នុងអាជីពការងារដែលបានរៀបរាប់ខាងនោះដែរ។ លើសពីនេះទៀត មិនមែនគ្រប់អ្នកទទួលបានការអប់រំជាន់ខ្ពស់ រួមទាំងអ្នកទទួលបានសញ្ញាបត្របណ្ឌិត គឺជាបញ្ញវន្តសាធារណៈនោះដែរ។ និយាយដោយខ្លី បញ្ញវន្តសាធារណៈ មិនត្រូវបានវាស់វែងលើកម្រិតនៃការអប់រំផ្លូវការដែលពួកគេទទួលបាន ឬអាជីពការងាររបស់ពួកគេនោះទេ ទោះបីជាការអប់រំផ្លូវការ និងអាជីពការងាររបស់ពួកគេ គឺជាលក្ខខណ្ឌចាំបាច់មួយដែលធ្វើឱ្យពួកគេមានសក្តានុពលក្លាយជាបញ្ញវន្តសាធារណៈក៏ដោយ។

នៅក្នុងសៀវភៅ "Public Intellectuals: An Endangered Species?" បានលើកឡើងពីនិយមន័យដែលយល់ស្របគ្នាជាទូទៅថា បញ្ញវន្តសាធារណៈ គឺជាអ្នកដែលបញ្ចេញយោបល់ជាសាធារណៈលើបញ្ហាផ្សេងៗជាច្រើន ទាក់ទងនឹងប្រយោជន៍សាធារណៈទូទៅ ហើយមិនរក្សាគំនិតទាំងនេះនៅក្នុងខ្លួនតែម្នាក់ឯងនោះទេ។ ពួកគេជាអ្នកមានចំណេះដឹងទូទៅទូលំទូលាយ និងមិនមែនជាអ្នកឯកទេសនោះទេ។[3]

ដោយសារតែការបញ្ចេញយោបល់ជាសាធារណៈ ទៅដល់មនុស្សជាច្រើនក្នុងយុគសម័យបច្ចេកវិទ្យានេះមិនអាចរំលងប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយការទទួលយកយោបល់ពីសាធារណៈជនក៏មិនអាចរំលងប្រព័ន្ធអ៊ីនធឺណេត ខ្ញុំស្នើសុំឲ្យអ្នកអានសាកល្បងស្វែងរកថាអ្នកណាជាបញ្ញវន្តសាធារណៈ តាមរយៈការវាយពាក្យ ជាភាសាខ្មែរ "បញ្ញវន្តសាធារណៈ" និងភាសាអង់គ្លេស "Public Intellectual" នៅលើប្រព័ន្ធអ៊ីនធឺណេត និងបណ្តាញសង្គមនានា ហើយសិក្សាប្រៀបធៀប និងសាកឆ្លើយថា លទ្ធផលទាំងនេះអាចចាត់ទុកជាបញ្ញវន្តសាធារណៈ ជាពិសេសសម្រាប់សង្គមកម្ពុជាបានដែរឬទេ?

ប្រសិនបើចម្លើយថា **ទេ**! យើងអាចចោទសួរបន្តទៀតថា តើលក្ខណវិនិច្ឆ័យណាខ្លះ ដែលអាចឱ្យយើងហៅនរណាម្នាក់ថាជាបញ្ញវន្តសាធារណៈ ឬវាស់វែងលើគំនិតរបស់នរណាម្នាក់ថាជាបញ្ញវន្តសាធារណៈ?

ប្រសិនបើគ្រាន់តែការនិយាយ ឬសរសេរអំពីបញ្ហាដែលទាក់ទងនឹងប្រយោជន៍សាធារណៈ ដោយមិនមានស្តង់ដារបញ្ញាសម្រាប់វាស់វែងក្នុងការកំណត់ថា អ្នកណាជាបញ្ញវន្តសាធារណៈ ប្រហែលជាយើងមាននិយមន័យច្រើនយ៉ាងអំពី

[2] អត្រាចុះឈ្មោះចូលរៀននៅកម្រិតឧត្តមសិក្សានៅកម្ពុជាមានចំនួន១៥% បើធៀបជាមួយពិភពលោកដែលមាន៣៨% ហើយវៀតណាមនៅជាប់កម្ពុជាមាន២៨% ឯថៃមាន៤៩% ក្នុងឆ្នាំ២០១៦ (ប្រភព៖ UNESCO Institute for Statistics (uis.unesco.org). Data as of September 2020)។

[3] A. Etzioni, & A. Bowdith (Eds.), *Public Intellectuals: An Endangered Species?* (Rowman & Littlefield, 2006, p.1)។

បញ្ញវន្តសាធារណៈថាជាអ្នកឯកទេសក្នុងវិស័យណាមួយ ថាជាអ្នកសារព័ត៌មានដ៏ឆ្នើម ថាជាអ្នករក្សានិងបន្តពុទ្ធិ (ទុកសម្រាប់ជំនាន់ក្រោយ) ថាជាអ្នកបង្ហាញសច្ចភាព (អ្នកស្រាវជ្រាវ/រុករក) ថាជាអ្នកគិត (អ្នកដោះស្រាយល្បែងបង្គំរូបភាព) ឬថាជាអ្នកគិតសេរី (អំពីបញ្ហាដែលចាត់ទុកថាមានភាពចាំបាច់ និងមានសារសំខាន់សម្រាប់សង្គមជាតិជាសាធារណៈ)។

នៅទីនេះ ខ្ញុំដើរតាម John Issitt និង Duncan Jackson ក្នុងអត្ថបទពួកគេ ក្រោមចំណងជើង "តើបញ្ញវន្តសាធារណៈមានន័យជាអ្វី?" ដែលអះអាងថា បញ្ញវន្តសាធារណៈទាំង៥ខាងលើពិតជាមានព្រំដែនក្នុងនិយាយ ឬសរសេរអំពីបញ្ហាសាធារណៈ ប្រសិនបើមិនទាក់ទងនឹងផលប្រយោជន៍បុគ្គលដូចជាតម្រូវការរកប្រាក់ចំណូល ឬការរីកចម្រើនក្នុងអាជីពការងារ ក៏ត្រូវបានកំណត់ដោយវប្បធម៌ស្ថាប័នដែលពួកគេកំពុងធ្វើការងារ ទោះបីជាពួកគេជាអ្នកគិតក៏ដោយ ឧទាហរណ៍ជាអ្នកស្រាវជ្រាវ ឬសាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលលទ្ធផលស្រាវជ្រាវ និងការវាយតម្លៃការងាររបស់ពួកគេគឺផ្អែកលើផលប៉ះពាក់ជាក់ស្តែង[4]។ មានតែអ្នកគិតសេរីទេដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងចាំបាច់ក្នុងការក្លាយជាបញ្ញវន្តសាធារណៈពិតប្រាកដ ពីព្រោះពួកគេមានភាពឯករាជ្យពិតប្រាកដពីអាជីពការងាររបស់ខ្លួន ហើយពិភាក្សាអំពីនិយាមនៃវិចារណកិច្ចបញ្ហាសាធារណៈនានា ផ្អែកលើតក្កវិជ្ជា និងចេញពីជំហរទ្រឹស្តីពុទ្ធិច្បាស់លាស់។ បន្ថែមពីលើនេះ ពួកគេប្រកាន់ភ្ជាប់សីលវិជ្ជាជាក់លាក់ដែលបញ្ជាក់ពីជំហរ និងទំនួលខុសត្រូវសង្គមនៃនិយាមដែលពួកគេកំពុងតស៊ូមតិ ជាទូទៅជ្រកក្រោមទំនោរលើកកម្ពស់យុត្តិធម៌សង្គម និងកាតព្វកិច្ចសីលធម៌អន្តរជំនាន់ (ក្នុងជម្រើសនៃការប្រើប្រាស់ធនធានកម្រ) ទោះបីជាមិនមែនជាសមភាពជាច់ខាតក្នុងពិភពអចិន្តភាពក៏ដោយ តែវាជាភាពចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់ សុវត្ថិភាព និងដំណើរការសង្គមឱ្យមាននិរន្តរភាព និងចីរភាព។

ទោះជាមានឈ្មោះជាបញ្ញវន្តសាធារណៈក៏ដោយ ក្នុងនាមជាអ្នកស្វែងរកសោភណភាព និងអត្ថន័យនៃជីវិត ដែលមិនមែនគ្រាន់តែដើម្បីអ្នកដទៃ តែដើម្បីខ្លួនឯងដែលជាបុគ្គលស្ថិតនៅក្នុងកាល និងលំហ តែប្រហែលរស់នៅប្រកបដោយការឆ្លុះបញ្ចាំងជាងមនុស្សដទៃទៀត គាត់ត្រូវតែលាតត្រដាងពីបទពិសោធន៍នៃគំនិតអំពីរបៀបនៃការរស់នៅជាលក្ខណៈបុគ្គលរបស់គាត់តាមរយៈអត្ថបទសំណេរ និងសិល្បៈ (ទាំងគួរតែ/មិនគួរតែ និងត្រូវតែ/មិនត្រូវតែ)។ បទពិសោធន៍ដែលអ្នកដទៃអាចរៀនសូត្រ និងយកទៅពិចារណាសម្រាប់ជាមាគ៌ានៃជីវិតរបស់ខ្លួន។

តើបញ្ញវន្តសាធារណៈបែបនេះកើតឡើងដោយរបៀបណា? វាត្រូវតែមានបរិយាកាសដ៏សមស្របមួយសម្រាប់ឱ្យបញ្ញវន្តម្នាក់នេះលេចឡើង ដើម្បីក្លាយជាអ្នកដឹកនាំ/សម្របសម្រួលក្រុមបញ្ញវន្ត រួចបន្តចលនាបញ្ញវន្តសាធារណៈ មានន័យថាអនុញ្ញាតឱ្យគំនិតបញ្ញវន្តសាធារណៈបែបនេះហូរចេញពីក្រុមចង្អៀតនេះទៅកាន់មហាជន និងសង្គមទូទៅ។ ដោយជាក់ច្បាស់ បរិយាកាសបែបនេះអាចកើតឡើងតែនៅក្នុងលំហសាធារណៈប៉ុណ្ណោះ ហើយសាកលវិទ្យាល័យរដ្ឋ និងធនាគារខួរក្បាល គឺជាទីកន្លែងដែលមានភាពសមស្របបំផុត។

តើអ្នកណាជាអ្នកបង្កើតស្ថាប័នបែបនេះ? កាលពីសម័យបុរាណ ទីកន្លែងសិក្សាជាន់ខ្ពស់ ដែលមានឋានៈស្មើសាកលវិទ្យាល័យ និងធនាគារខួរក្បាលដូចដែលយើងស្គាល់សព្វថ្ងៃនេះ កើតឡើងដោយការគាំទ្រ និងឧបត្ថម្ភពីសំណាក់ព្រះមហាក្សត្រ ដែលចង់ឃើញដែនអាណាចក្រនៃការគ្រប់គ្រងរបស់ព្រះអង្គ ពោរពេញទៅដោយគំនិតបែបនេះ ដើម្បីជួយជ្រោមជ្រែងព្រះអង្គក្នុងដំណើរការដឹកនាំចក្រភព របស់ព្រះ

[4] John Issitt and Duncan Jackson March (2013). 'What does it mean to be a public intellectual?, Retrieved from https://www.heacademy.ac.uk/sites/default/files/resources/12_march_presentation.pdf, ចូលថ្ងៃទី១២ មីនា ឆ្នាំ២០២១។

អង្គ។ ក្នុងន័យសាសនា ទីកន្លែងបែបនេះ កើតឡើងនៅក្នុងសហគមន៍សាសនា ដែលជជែកវែកញែកពីរបៀបរស់នៅ និងសណ្ដាប់សង្គម ទោះបីជាត្រូវបានដាក់ព្រំដែនឱ្យនៅក្រោមគម្ពីរសាសនាក៏ដោយ។ ក្រោយមក នៅក្នុងយុគនៃការកកើតឡើងនូវរដ្ឋស៊ីវិល សាកលវិទ្យាល័យជាតិ ត្រូវបានកើតឡើងក្រោមការគាំទ្រដោយហិរញ្ញប្បទានសាធារណៈ ដើម្បីជួយគាំទ្ររដ្ឋាភិបាល និងថ្នាក់ដឹកនាំក្នុងកិច្ចអភិវឌ្ឍប្រទេសជាតិ។

ការរីកចម្រើននៃមូលធននិយម និងការជឿជាក់លើការអនុវត្តតក្កវិជ្ជាទីផ្សារសេរី ក្នុងអំឡុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ បានដកហូតតួនាទីហិរញ្ញប្បទានសាធារណៈ ក្នុងការគាំទ្រសាកលវិទ្យាល័យរដ្ឋ និងធនាគារខួរក្បាលឯករាជ្យ និងដាក់ជំនួសមកវិញដោយហិរញ្ញប្បទានឯកជន និងអន្តរជាតិ ហើយនេះបានបង្វែរអ្នកគិតសេរីឱ្យនៅត្រឹមកម្រិតអ្នកគិត និងបង្វែរទិសការអប់រំជាន់ខ្ពស់ ចេញពីការគិតគូរពីភាពល្អជាសាធារណៈ ជាពិសេសសម្រាប់សង្គមជាតិខ្លួនទៅរកអាជីពការងារសម្រាប់តែការបម្រើឱ្យប្រយោជន៍នៃវឌ្ឍភាពមូលធននិយម និងទីផ្សារសេរីតែមួយគត់ និងជួនកាលបញ្ហាសាកលលោក ដែលមានការពាក់ព័ន្ធតិចតួចបំផុតទៅនឹងសង្គមជាតិដែលពួកគេកំពុងរស់នៅ[5]។ ទីណាដែលមានវឌ្ឍភាពមូលធននិយម និងទីផ្សារសេរី ដោយគ្មានអំណាចរដ្ឋដើម្បីភាពល្អជាសាធារណៈ លំហគំនិតបញ្ញវន្តសាធារណៈកាន់តែរួមតូចទៅៗ មិនមែនតែនៅកម្ពុជា ប៉ុន្តែនៅទូទាំងពិភពលោកផងដែរ។

អ្វីដែលគួរឱ្យកត់សម្គាល់គឺថា ទីណាដែលមានវឌ្ឍនភាពមូលធននិយម និងទីផ្សារសេរី ដោយគ្មានអំណាចរដ្ឋខ្លាំងក្លា គឺជាទីដែលវិសមភាពសង្គមកាន់តែមានគម្លាតធំឡើងៗ។ នៅក្នុងរយៈពេលវែង គឺវិសមភាពសង្គមនេះហើយដែលនាំមកនូវភាពប្រេបូកប្រេបល់ និងអសន្តិសុខ ដែលនាំឱ្យសណ្ដាប់សង្គមរង្គោះរង្គើរ។ នៅពេលណាដែលវឌ្ឍនភាពមូលធននិយម និងទីផ្សារសេរីកាន់តែដាច់បង្អៀរ វាគឺជាពេលវេលាមួយដែលសមស្របបំផុតសម្រាប់អំណាចរដ្ឋចូលត្រឡប់មកវិញ មកគិតគូរ និងលើកកម្ពស់គំនិតបញ្ញវន្តសាធារណៈ តាមរយៈការបង្កើនល្បឿននៃការគាំទ្រសាកលវិទ្យាល័យរដ្ឋ ធនាគារខួរ-ក្បាលឯករាជ្យ ដើម្បីទប់ស្កាត់ឱ្យទាន់ពេលវេលាការកកើតឡើងនូវភាពប្របូកប្របល់ និងអសន្តិសុខ ដែលនាំឱ្យសណ្ដាប់ធ្នាប់សង្គមរង្គោះរង្គើរ។ ភាពប្របូកប្របល់ និងអសន្តិសុខសង្គម មិនមែនជាបញ្ហានយោបាយ ក្នុងន័យជាការប្រកួតប្រជែងដើម្បីអំណាច និងយោធានោះទេ តែជាបញ្ហាអយុត្តិធម៌សង្គម ដែលអាចត្រូវបានដោះស្រាយតាមរយៈគំនិតបញ្ញវន្តសាធារណៈតែមួយគត់។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

[5] នេះវាមិនមែនជាអ្វីដែលអាក្រក់ដាច់ខាតនោះទេ តែអ្វីដែលយើងត្រូវឆ្ងល់ និងគួរតែសួរខ្លួនឯងនោះគឺសំណួរដែលថា តើអ្នកណាជាអាទិភាពនៃការបម្រើរបស់យើង។